**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការពារជាតិ**
**អគ្គនាយកដ្ឋាននយោបាយ និងកិច្ចការបរទេស**
លេខ..............................................

# សេចក្តីប្រកាសព័ត៌មាន

នៅព្រឹកថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២២ ក្រសួងការពារជាតិបានធ្វើពិធីប្រកាសចេញផ្សាយជាផ្លូវការ និងជាសាធារណៈ នូវសៀវភៅសការពារជាតិឆ្នាំ២០២២ (DWP2022) និងការផ្សព្វផ្សាយទូលាយការធ្វើជាម្ចាស់ផ្ទះនៃកិច្ចប្រជុំរដ្ឋមន្ត្រីការពារជាតិអាស៊ានឆ្នាំ២១២២ (ADMM2022) និងកិច្ចប្រជុំពាក់ព័ន្ធ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់**សម្តេចពិជ័យសេនា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ។ ពិធីនេះ មានការចូលរួមពីសំណាក់នាយទាហានជាន់ខ្ពស់នៃកងយោធពលខេមរភូមិន្ទ តំណាងក្រសួងនិងស្ថាប័នរាជរដ្ឋាភិបាលនិងស្ថាប័នក្រៅរដ្ឋាភិបាលដែលពាក់ព័ន្ធ និងបណ្តាអនុព័ន្ធយោធានិងតំណាងស្ថានទូតបរទេសប្រចាំព្រះរាជាណាចក្រកម្ពុជា សរុបចំនួនជាងបួនរយនាក់។

នៅក្នុងឱកាសនោះ **សម្តេចពិជ័យសេនា**បានគូសបញ្ជាក់លើខ្លឹមសារសំខាន់ៗមួយចំនួន មានជាអាទ៍៖

ដោយហេតុថាសៀវភៅសការពារជាតិឆ្នាំ២០២២ គឺជាគោលនយោបាយយុទ្ធសាស្ត្ររយៈពេលវែងរបស់ព្រះរាជាណាចក្រកម្ពុជា ក្នុងវិស័យការពារជាតិនិងសន្តិសុខ ហើយដែលត្រូវបានផ្តល់សច្ចាប័នដ៏ខ្ពង់ខ្ពស់ដោយ **សម្តេចតេជោ នាយករដ្ឋមន្ត្រី** តម្រូវឲ្យចាត់ទុកឯកសារនេះជាត្រីវិស័យនិងជាគោលការណ៍សម្រាប់ការរៀបចំផែនការយុទ្ធសាស្ត្រ ការធ្វើកំណែទម្រង់យោធា និងការកសាងសមត្ថភាពកងយោធពលខេមរភូមិន្ទ។ ទន្ទឹមនឹងនេះ សៀវភៅសការពារជាតិឆ្នាំ២០២២ គឺជាឧបករណ៍ដ៏សំខាន់នៅក្នុងទំនាក់ទំនងអន្តរជាតិ ជាពិសេសសុឆន្ទៈរបស់កម្ពុជា នៅក្នុងការកសាងទំនុកចិត្តនិងតម្លាភាពជាមួយបណ្តាប្រទេសនៅក្នុងតំបន់។

សន្តិភាពដ៏កម្ររកបាននៅកម្ពុជា ទាមទារឲ្យមានការថែរក្សាការពារឲ្យបានជាដាច់ខាត ទោះក្នុងតម្លៃណាក៏ដោយ។ ត្រូវចាត់វិធានការជាបន្ទាន់ចំពោះរាល់សកម្មភាពទាំងឡាយណា ដែលមានចរិតជាបដិវត្តន៍ពណ៌ ដើម្បីភាពសុខដុមរមនា និងវិបុលភាពរបស់ប្រជាជាតិកម្ពុជា។ ទន្ទឹមនឹងនេះ ត្រូវលើកស្ទួយតម្លៃនិងខិតខំកសាងតឹកតាងនៃប្រវត្តិសាស្ត្រយោធា ដែលជាមូលដ្ឋានគ្រឹះនៃនយោបាយឈ្នះ ឈ្នះ នាំមកនូវសន្តិភាពនិងឯកភាពជាតិពេញលេញ រហូតដល់សព្វថ្ងៃនិងតទៅថ្ងៃអនាគត។

ការផ្សារភ្ជាប់ទំនាក់ទំនងរវាងសមរភូមិមុខនិងសមរភូមិក្រោយ គឺជាកត្តាមិនអាចខ្វះបានសម្រាប់ទ្រទ្រង់ដល់ខឿនការពារជាតិ។ សម្ព័ន្ធមេត្រីភាពរវាងកងទ័ព និងស្ថាប័នរដ្ឋនិងឯកជន នឹងលើកតម្លៃនៃពលិកម្មដ៏ធំធេងរបស់កងទ័ព និងបង្កើនការគាំទ្រទាំងស្មារតី និងសម្ភារៈ ពីសំណាក់សមរភូមិក្រោយ។

ចាប់ពីពេលនេះតទៅ ការធ្វើទំនើបកម្មកងយោធពលខេមរភូមិន្ទ គឺជាអាទិភាពចម្បងមួយ នៅក្នុងដំណើរការកែទម្រង់យោធា។ សមត្ថភាពកងយោធាកម្ពុជា នឹងមិនត្រូវបានចាប់បង្ខំឲ្យស្ថិតនៅក្នុងសភាពចាស់គម្រិលគោកយ៉ាក ឬដើរថយក្រោយ នោះឡើយ។ ការធ្វើទំនើបកម្ម នឹងមិនមានត្រឹមតែមូលដ្ឋានកងទ័ពជើងទឹករាម



ក្រសួងការពារជាតិ មហាវិថីសហព័ន្ធរុស្ស៊ី រាជធានីភ្នំពេញ ទូរស័ព្ទ: (៨៥៥-៧៩) ៧៧៧ ៥១៥

ប៉ុណ្ណោះទេ តែនឹងត្រូវធ្វើនៅក្នុងវិស័យផ្សេងៗទៀត ដូចជាការពារអាកាស អាវុធធុនធ្ងន់ ការសង្គ្រោះ ប្រតិបត្តិការរក្សាសន្តិភាព ការប្រឆាំងអំពើភេរវកម្មនិងឧក្រិដ្ឋកម្មឆ្លងដែន ជាដើម។ ការធ្វើទំនើបកម្មនេះ មិនមែនបង្កការគំរាមកំហែងដល់ប្រទេសណាមួយនោះឡើយ ផ្ទុយទៅវិញ ជាការការពារខ្លួន និងរួមចំណែកក្នុងការថែរក្សាសន្តិភាព និងស្ថិរភាពនៅក្នុងតំបន់ តែប៉ុណ្ណោះ។

សម្រាប់កិច្ចប្រជុំ ADMM2022 ដែលកម្ពុជាធ្វើជាម្ចាស់ផ្ទះ **សម្តេចពិជ័យសេនា**បានវាយតម្លៃខ្ពស់ចំពោះដំណើរការមកទល់នឹងពេលនេះ ទាំងជោគជ័យនៃកិច្ចប្រជុំដែលបានធ្វើរួចមកហើយ ក៏ដូចជាការព្រមព្រៀងលើឯកសារទស្សនទានមួយចំនួន ដែលភាគច្រើនផ្តួចផ្តើមដោយកម្ពុជា។ យើងកំពុងមមាញឹកនៅក្នុងការរៀបចំកិច្ចប្រជុំ ADMM នៅក្នុងខែមិថុនា និងកិច្ចប្រជុំ ADMM បូក នៅក្នុងខែវិច្ឆិកា ស្របតាមមូលបទ "**សាមគ្គីភាពដើម្បីសន្តិសុខប្រកបដោយសុខដុម**"។ ទោះជាបានទទួលនូវលទ្ធផលជាវិជ្ជមានយ៉ាងណាក៏ដោយ កិច្ចប្រជុំ ADMM និង ADMM បូក នាពេលខាងមុខ កំពុងប្រឈមជាមួយនឹងការលំបាកខ្លះៗ ដែលបណ្តាលមកពីបញ្ហាមីយ៉ាន់ម៉ា សង្គ្រាមរវាងរុស្ស៊ីនិងអ៊ុយក្រែន និងការប្រែប្រួលយ៉ាងឆាប់រហ័សផ្នែកភូមិសាស្ត្រនយោបាយនៅក្នុងតំបន់។

ដោយសារបញ្ហាទាំងពីរនេះ ប្រទេសអាស៊ាននិងប្រទេសជាដៃគូសន្ទនាមួយចំនួន កំពុងមានការពិនិត្យនិងពិចារណាលើការចុះហត្ថលេខាលើសេចក្តីប្រកាសរួម ដែលតំណាងឲ្យការពង្រឹងឯកភាពនិងមជ្ឈភាពរបស់អាស៊ាន ព្រមទាំងឆ្លុះបញ្ចាំងអំពីកិច្ចសហប្រតិបត្តិការជាក់ស្តែងរវាងអាស៊ាននិងប្រទេសបូក។ ក្នុងឋានៈជាម្ចាស់ផ្ទះ យើងពិតជាមិនចង់ឃើញទិដ្ឋភាពបែបនេះកើតឡើងនៅកម្ពុជា ដែលជាបច្ច័យមិនល្អ និងអាចក្លាយជាទម្លាប់ឬជាប្រពៃណី តទៅថ្ងៃអនាគត។ **សម្តេចពិជ័យសេនា** បានអំពាវនាវដល់ភាគីពាក់ព័ន្ធទាំងអស់ ឲ្យមានការយោគយល់ ដើម្បីរួមគ្នាបញ្ចៀសបញ្ហានេះ។

បញ្ហាមួយទៀតគឺ កិច្ចប្រជុំក្រៅផ្លូវការរវាងរដ្ឋមន្ត្រីការពារជាតិអាស៊ាននិងរដ្ឋមន្ត្រីការពារជាតិនៃប្រទេសបូកមួយចំនួន។ សម្រាប់ឆ្នាំនេះ កម្ពុជាបានទទួលសំណើពីប្រទេសបូកចំនួនប្រាំពីរ ហើយកម្ពុជាមានបំណងចង់ទទួលរៀបចំកិច្ចប្រជុំក្រៅផ្លូវការសម្រាប់ប្រទេសបូកទាំងនោះ ដោយហេតុថា ជាការជួបគ្នាដោយផ្ទាល់លើកដំបូងបន្ទាប់ពីការចាប់ផ្តើមនៃជំងឺកូវីដ១៩។ លើសពីនេះទៀត វាជាឱកាសល្អមួយសម្រាប់ការប្រឹក្សាផ្លាស់ប្តូរយោបល់អំពីការវិវត្តន៍នៃសភាពការថ្មីៗនៅទូទាំងពិភពលោក ផងដែរ។ ក៏ប៉ុន្តែ សុឆន្ទៈរបស់កម្ពុជាកំពុងប្រឈមជាមួយនឹងគោលការណ៍របស់ ADMM ដែលបានព្រមព្រៀងគ្នាកាលពីឆ្នាំ២០២១ ក្នុងនោះកំណត់ឲ្យមានកិច្ចប្រជុំក្រៅផ្លូវការត្រឹមតែបួនប៉ុណ្ណោះ ក្នុងមួយឆ្នាំ។ ចំពោះករណីនេះ **សម្តេចពិជ័យសេនា**បានទទូចស្នើសុំឲ្យមានការយោគយល់ និងមានភាពបត់បែន ដើម្បីប្រយោជន៍រួមរបស់អាស៊ាន។

**សម្តេចពិជ័យសេនា**បានកោតសរសើរនិងវាយតម្លៃខ្ពស់ចំពោះការចូលរួមយ៉ាងសកម្មនិងប្រកបដោយជោគជ័យត្រចះត្រចង់របស់កងយោធពលខេមរភូមិន្ទ នៅក្នុងយុទ្ធនាការប្រយុទ្ធនឹងជំងឺកូវីដ១៩ ក្នុងពេលកន្លងមក និងស្នើឲ្យបន្តសកម្មភាពចាក់វ៉ាក់សាំងជូនប្រជាពលរដ្ឋ ស្របតាមគោលការណ៍របស់រាជរដ្ឋាភិបាល។

ថ្ងៃព្រហស្បតិ៍ ១២កើត ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២២
**អគ្គនាយកដ្ឋាននយោបាយ និងកិច្ចការបរទេស**